# ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

**VOTE 2026**

អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅ បោះឆ្នោតដោយគ្មានការកាត់
ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

និយោជករបស់អ្នកត្រូវទូទាត់ប្រាក់ជូនអ្នកសម្រាប់ពេលវេលាដែលអ្នកត្រូវទៅបោះឆ្នោត ប្រសិនបើថ្ងៃបោះឆ្នោតចំម៉ោងការងារធម្មតារបស់អ្នក។ និយោជករបស់
អ្នកមិនអាចតម្រូវឱ្យអ្នកប្រើប្រាស់ថ្ងៃឈប់សម្រាកផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

ចំណាយពេលវេលាដែលអ្នកត្រូវការចាំបាច់ដើម្បីទៅបោះឆ្នោត និងទៅធ្វើការ។

និយោជករបស់អ្នកមិនអាចបដិសេធ ដាក់កំហិត ឬរំខានដល់សិទ្ធិនេះដោយផ្ទាល់ ឬដោយប្រយោល ឡើយ រួមទាំងការជ្រើសរើសពេលវេលារបស់អ្នកដើម្បី ទៅបោះឆ្នោតផងដែរ។
និយោជករបស់អ្នកអាចសុំឱ្យអ្នកប្រាប់គាត់អំពីពេលវេលាដែលអ្នកត្រូវទៅ និងសុំឱ្យបុគ្គលិកជួយសម្របសម្រួលអវត្តមានរបស់ខ្លួនដើម្បីកាត់បន្ថយការអាក់ខាននៅកន្លែងធ្វើការ។

**កាលបរិច្ឆេទឆ្នាំ *2026***

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី*11* ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី*18* ខែកញ្ញា រហូតដល់ថ្ងៃទី*2*ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃ ទី*13* ខែតុលា ដើម្បីសន្សំ សំចៃពេលវេលានៅថ្ងៃ បោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី*3* ខែវិច្ឆិកា

អ្នកមានសិទ្ធិឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត នៅក្នុងគ្រប់ការបោះឆ្នោតប្រចាំរដ្ឋ និងសហព័ន្ធ និង នៅក្នុងគ្រប់ការបោះឆ្នោតក្នុងមូលដ្ឋានដែលបានកំណត់ពេលជាទៀងទាត់។

តទៅទំព័រក្រោយ...

ការិយាល័យលេខាធិការរដ្ឋ *Minnesota*
*mnvotes.gov • 1-877-600-VOTE*

TIME OFF WORK - updated 12/11/2025

TIME OFF WORK - updated 12/11/2025

# ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

VOTE 2026

.... តពីទំព័រមុខ

## ការដាក់ពាក្យប្តឹង

និយោជកដែលរំលោភទៅលើច្បាប់នេះគឺមានបទល្មើសមជ្ឈិម។ រាល់បណ្តឹងពីបុគ្គលិកគួរដាក់ប្តឹងទៅមេធាវី ប្រចាំក្រុង។

## បោះឆ្នោតមុនពេលដោយប្រើសន្លឹកឆ្នោតសម្រាប់អ្នកអវត្តមាន

អ្នកអាចបោះឆ្នោតមុនពេលបាន ប្រសិនបើអ្នកមិនចង់ ឬមិនអាចបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេ។ សិទ្ធិឈប់សម្រាកពីការងារដើម្បីបោះឆ្នោតត្រូវបានពង្រីក ដើម្បីរួមបញ្ចូលពេលណាក៏បានក្នុងអំឡុងរយៈពេលបោះឆ្នោតដោយអវត្តមាន ដែលចាប់ផ្តើមមុនថ្ងៃបោះឆ្នោត 46 ថ្ងៃ។

អ្នកអាចបោះឆ្នោតមុនពេលបានដោយប្រើសន្លឹកឆ្នោតសម្រាប់អ្នកអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក។ អ្នកក៏អាចស្នើឱ្យផ្ញើសន្លឹកឆ្នោតសម្រាប់អ្នកអវត្តមានតាមសំបុត្រឱ្យអ្នកបានផងដែរដោយចូលទៅកាន់ mnvotes.gov/absentee។

**លិខិតសម្រាប់និយោជករបស់អ្នក**
សូមចូលទៅកាន់គេហទំព័រ *mnvotes.gov* ដើម្បី ស្វែងរកលិខិតដែលអ្នកអាចផ្តល់ជូននិយោជករបស់អ្នក ដើម្បីពន្យល់អំពីសិទ្ធិរបស់អ្នកក្នុងការឈប់សម្រាក ដើម្បីទៅបោះឆ្នោត។

ការិយាល័យលេខាធិការរដ្ឋ *Minnesota*
*mnvotes.gov • 1-877-600-VOTE*